KHMER

fka CHILDREN'S SERVICES INC

# ការរក្សាទុកភាសាគ្រួសាររបស់អ្នក

ការរក្សាទុកភាសាគ្រួសាររបស់អ្នក បង្កើតជាគ្រឹះសម្រាប់គ្រប់ការអភិវឌ្ឍភាសានៅពេលក្រោយៗ។ កូនរបស់អ្នកអាចទទួលបានភាសាច្រើនយ៉ាងងាយ ពេលណាពួកគេមានឱកាសដើម្បីមើល ឃើញ ស្តាប់ និងប្រាស្រ័យទាក់ទងជាមួយគំរូភាសាដ៏រឹងមាំ។

អ្នកវិជ្ជាជីវៈកុមារតូចក្នុងរដ្ឋវិចថូរៀ ត្រូវបានណែនាំដោយ *ក្របខ័ណ្ឌការរៀនសូត្រ និងការអភិវឌ្ឍកុមារតូចរដ្ឋវិចថូរៀ* (VEYLDF)។ ក្របខ័ណ្ឌនេះទទួលស្គាល់ពហុភាសានិយមថាជាទ្រព្យសម្បត្តិ ហើយបង្កើតការរំពឹងទុកថា កុមារនឹងទទួលបានការគាំទ្រក្នុងការរក្សាទុកភាសាគ្រួសារ រៀនភាសាអង់គ្លេសជាភាសាបន្ថែម និងរៀនភាសាក្រៅពីភាសាអង់គ្លេស នៅពេលចូលរួមកម្មវិធីអប់រំ និងការថែទាំកុមារតូច (VEYLDF, 2016)។

មានអត្ថប្រយោជន៍ជាច្រើនសម្រាប់កូនរបស់អ្នកក្នុងការរក្សាទុក និងបន្តអភិវឌ្ឍភាសាគ្រួសាររបស់ពួកគេ៖

- កូនរបស់អ្នកអាចពង្រីកភាពបត់បែន និងការអភិវឌ្ឍដែលមានការចងចាំរបស់ពួកគេ តាមរយៈការប្រើប្រាស់ភាសាគ្រួសាររបស់អ្នក។
- ការរក្សាទុកភាសាគ្រួសាររបស់អ្នកគឺចាំបាច់សម្រាប់ទំនាក់ទំនងគ្រួសារ បង្កើតការភ្ជាប់ទំនាក់ទំនង និងអារម្មណ៍នៃភាពជាកម្មសិទ្ធិ។
- ភាសាគ្រួសារត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងអត្តសញ្ញាណវប្បធម៌ និងសុខុមាលភាពរបស់កូនអ្នក។
- ភាពស្ទាត់ជំនាញក្នុងភាសាគ្រួសាររបស់អ្នក គាំទ្រកូនរបស់អ្នកឱ្យរៀនភាសាបន្ថែម ដូចជាភាសាអង់គ្លេស។

VEYLDF (2016) ពន្យល់ដល់អ្នកអប់រំថា ‛ការទទួលបាន និងការរក្សាទុកភាសាទីមួយ ឬភាសាដើម មានតួនាទីសំខាន់ និងបន្តក្នុងការកសាងអត្តសញ្ញាណ′ (ទំព័រ 18)។ ដូច្នេះហើយ សមាសធាតុសំខាន់មួយនៃការគាំទ្រដល់ការអភិវឌ្ឍភាសាអង់គ្លេសជាភាសាបន្ថែម គឺសម្រាប់អ្នកអប់រំ និងក្រុមគ្រួសារចូលរួមគ្នាក្នុងភាពជាដៃគូដែលសហការគ្នា ដើម្បីលើកទឹកចិត្ត និងគាំទ្រកុមារឱ្យរក្សាទុក និងបន្តអភិវឌ្ឍភាសាគ្រួសាររបស់ពួកគេ។

## ការអភិវឌ្ឍភាសាអង់គ្លេសជាភាសាបន្ថែមនៅក្នុងបរិដ្ឋានអប់រំ និងថែទាំកុមារតូច

កូនរបស់អ្នកនឹងមានឱកាសជាច្រើន ក្នុងការរៀនភាសាអង់គ្លេសនៅក្នុងបរិដ្ឋានអប់រំ និងថែទាំកុមារតូចរដ្ឋវិចថូរៀ។ ការស្រាវជ្រាវប្រាប់យើងថា ‛កុមារអាចរៀនភាសាអង់គ្លេស (ឬភាសាផ្សេងទៀត) ជាភាសាបន្ថែមដោយជោគជ័យ តាមរយៈការជាក់ប៉ះនឹងភាសា ការធ្វើគំរូ និងការបង្រៀនភាសាយ៉ាងជាក់លាក់ និងពេលវេលាសមស្របដើម្បីទទួលបានភាសាថ្មី′ (VEYLDF, 2016 ទំព័រ 22)។

ការស្គាល់ភាសាមួយ អាចជួយឱ្យកុមារយល់ពីរបៀបដែលភាសាផ្សេងទៀតដំណើរការ។ ជំនាញដែលកុមារអភិវឌ្ឍក្នុងភាសាមួយ អាចផ្ទេរទៅភាសាថ្មីមួយទៀត។ តាមរយៈភាសាគ្រួសារ ដែលកុមារអាចយល់ដឹងពីភាសាថ្មី វិធាន និងវាក្យសព្ទរបស់វា។ នៅពេលដែលកូនរបស់អ្នកបានជ្រួតជ្រាបក្នុងបរិដ្ឋានភាសាអង់គ្លេស ពួកគេនឹងមានឱកាសស្តាប់ភាសាអង់គ្លេសក្នុងបរិបទផ្សេងៗគ្នា។ ពួកគេនឹងចង់ចូលរួម និងលេងជាមួយកុមារដទៃទៀត ហើយអ្នកអប់រំនឹងផ្តល់គំរូល្អ និងឱកាសជាច្រើនសម្រាប់កូនរបស់អ្នកដើម្បីស្តាប់ និងអនុវត្តភាសាអង់គ្លេស។

ជំនាញភាសាអភិវឌ្ឍក្នុងល្បឿនសមស្របទៅនឹងបទពិសោធន៍ភាសាមុនរបស់កុមារ ជាក់ប៉ះនឹងនឹងភាសាថ្មី និងបរិដ្ឋានថ្មីដែលពួកគេកំពុងរៀនសូត្រ។ កុមាររៀនចេះភាសាច្រើនក្នុងពេលតែមួយ ក្នុងរយៈពេលមួយ អាចនិយាយច្រើនក្នុងមួយភាសា ច្រើនជាងមួយភាសាផ្សេងទៀត។ ដំបូង កុមារអាចលាយឡំភាសានៅពេលពួកគេនិយាយ។ ពួកគេប្រហែលជាស្គាល់ពាក្យនោះក្នុងភាសាមួយ ហើយមិនស្គាល់ពាក្យដដែលនោះ ក្នុងភាសាផ្សេងទៀត។ ដើម្បីរក្សាភាពស្ទាត់នៃការសន្ទនារបស់ពួកគេ ពួកគេប្រើពាក្យដែលគេស្គាល់។ នេះគឺជាជំនាញពីកំណើត និងអាចបត់បែនបាន ដែលកុមារអភិវឌ្ឍនៅពេលពួកគេប្រើភាសារបស់ពួកគេកាត់បរិបទពហុភាសា។

## សូមចងចាំ ...

វាត្រូវការពេលវេលាដើម្បីអភិវឌ្ឍភាពស្ទាត់ជំនាញការសន្ទនាក្នុងភាសាថ្មី ហើយកុមារត្រូវការពេលវេលា និងការគាំទ្រដោយគ្មានការដាក់សម្ពាធពីមនុស្សពេញវ័យ ដែលនៅជុំវិញពួកគេ នៅពេលពួកគេឆ្លងកាត់ដំណើរនៃការរៀនភាសាបន្ថែម។

នេះជាសិទ្ធិរបស់កុមារទាំងអស់ក្នុងការប្រើ និងរៀនភាសាគ្រួសាររបស់ពួកគេ (UNCRC, 1989)។

---


**References**

Department of Education and Training, 2016. *Victorian Early Years Learning and Development Framework.*

UNICEF, 1989. *United Nations Convention on the Rights of the Child* (UNCRN).